រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ១៣ អនក្រ
# ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើត ក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | ជាសហប្រធាន |
| ២- ឯកឧត្តម ម៉ុក ស៊ីវុទ្ធ | រដ្ឋមន្ត្រីទីស្តីគណៈរដ្ឋមន្ត្រី | ជាសហប្រធាន |
| ៣- ឯកឧត្តម សាយ បូរី | រដ្ឋលេខាធិការទំនាក់ទំនងជាមួយសភា | អនុប្រធាន |
| ៤- ឯកឧត្តម ហេង ចន្ទមុនីរ៉ាត | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ | អនុប្រធាន |
| ៥- ឯកឧត្តម អ៊ុក ចិន្តុន | ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ | សមាជិក |
| ៦- ឯកឧត្តម គង់ គិរុន | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ | សមាជិក |
| ៨- លោក កៅ ម៉ុនហុង | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- លោក ចន្ទ កានី | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០- លោក ហែម ក្រាញ់ភូនី | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**មាត្រា ២ :** ក្រុមប្រឹក្សាអ្នកច្បាប់មានភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកគំរោងកសាងច្បាប់ ឬ លិខិតបទដ្ឋានថ្មីៗ ដែលមានការចាំបាច់សំរាប់បំរើអោយសកម្មភាពរាជរដ្ឋាភិបាល ។
- សិក្សា និងតាមដាន អត្ថបទច្បាប់ និងលិខិតបទដ្ឋានទាំងឡាយដែលត្រូវបានប្រកាសចេញអោយប្រើ ដែលលែងសមស្រប និងសភាពការណ៍ជាក់ស្តែងដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលធ្វើវិសោធនកម្ម ។
- សិក្សា និង ផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រីអំពីសេចក្តីព្រាងច្បាប់លិខិតបទដ្ឋាន សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយជាមួយអន្តរជាតិ ដែលបណ្តាក្រសួងស្ថាប័ន ផ្ញើរមកសុំសេចក្តីអនុម័តពីគណៈរដ្ឋមន្ត្រី ។
- ចាត់ចែងផ្ញើសេចក្តីព្រាងច្បាប់ ឬ លិខិតបទដ្ឋានទៅជូនស្ថាប័នដែលមានសមត្ថកិច្ចផ្តល់សច្ចាប័នជាចុងក្រោយអោយបានសមស្របតាមនីតិវិធី ។

មាត្រា ៣ : ក្រុមប្រឹក្សាអ្នកច្បាប់ មានក្រុមជំនាញមួយជាជំនួយការដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-លោក ឡេង ប៉េងឡុង | ជាប្រធាន |
| ២-លោក ឡូ ប៉េន | ជាអនុប្រធាន |
| ៣-លោក គួច ចណ្ណលី | ជាអនុប្រធាន |
| ៤-លោក ឌី សូភីន | សមាជិក |
| ៥-លោក ភៅ តិចសរ | សមាជិក |
| ៦-លោក អ៊ុក សារី | សមាជិក |
| ៧-លោក គង់ ហេង | សមាជិក |

មាត្រា ៤ : សមាជិកទាំងអស់ ព្រមទាំងក្រុមជំនួយការរបស់ក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តមអស់លោក ដែលមាននាមក្នុងមាត្រា ១ និង មាត្រា ៣ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

***